00355904

លេខ/No: D130/8

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

Kingdom of Cambodia
Nation Religion King

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 28 / 07 / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Tuy

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ 002/19-09-2007-អ.វ.ត.ក.-ក.ស.ច.ស.**

ចំពោះមុខ៖ ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE (ម៉ាសែល ឡឺម៉ុង)

កាលបរិច្ឆេទ៖ ២៨ កក្កដា ២០០៩

ភាសាដើម៖ ខ្មែរ /បារាំង

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ (ឯកសារដែលមានការលុបចោលផ្នែកខ្លះ)

# ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម

**សហព្រះរាជអាជ្ញា**
ជា លាង
**Robert PETIT**

**ជនត្រូវចោទ**
អៀង ធីរិទ្ធ

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
នី ច័ន្ទី ឡោ ឈុនធី
គង់ ពិសី ហុង គឹមសួន
យុង ផានិត គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Phillipe CANONNE
Elizabeth Rabesandratana
Pierre-Olivier SUR
Mahdev MOHAN
Olivier BAHOUGNE
David BLACKMAN
Martine JACQUIN
Annie DELAHAIE

**មេធាវីការពារក្តី**
ផាត់ ពៅសៀង
Diana Ellis

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 29 / 07 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Tuy

យើង យូ ប៊ុនឡេង និង Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(" អ.វ.ត.ក")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញវិធាន ៥៥ (១០) នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ("វិធានផ្ទៃក្នុង")

បានឃើញការបើកការស៊ើបសួរលើឈ្មោះ អៀង ធីរិទ្ធ ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និង ជនផ្សេងទៀត ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក

បានឃើញសំណើសុំរបស់ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ (ក្រុមមេធាវីការពារក្តី)ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩ (D130)

បានឃើញការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩ (D130/5)

បានឃើញការឆ្លើយតបវិញរបស់ ក្រុមមេធាវីការពារក្តី ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ (D130/6)

**ឧត្តិករណ៍របស់ភាគី**

**ការស្នើសុំរបស់ក្រុមមេធាវីការពារក្តី**

១. មេធាវីការពារក្តីស្នើសុំសហចៅក្រមស៊ើបអង្កេត៖

ក) សម្រេចមិនទទួលយកនូវភស្តុតាងទាំងឡាយដែលទទួលបាន ឬដែលអាចទទួលបានដោយ ការធ្វើទារុណកម្ម លើកលែងតែដើម្បីបង្ហាញថា ការឆ្លើយសារភាពមួយទទួលបានតាមរយៈការធ្វើ

ទារុណកម្ម និងក្នុងលក្ខខណ្ឌថា ព័ត៌មាននៃភស្តុតាងនេះ ត្រូវបានប្រើប្រាស់ដើម្បីប្រឆាំងតែនឹងអ្នកធ្វើទារុណកម្មប៉ុណ្ណោះ។

ខ) សម្រេចមិនប្រើប្រាស់ចម្លើយសារភាព ក្រៅតែពីករណីដែលបានលើកឡើងខាងលើ ដូចជាការយកមកធ្វើជា "គម្រុយនៃការស៊ើបអង្កេត" ឬទទួលយកប្រភព ឬយោបល់អ្នកជំនាញនានាដែលផ្អែកលើចម្លើយសារភាពទាំងនេះ។

២. សំណើសុំនេះ ផ្អែកជាចម្បងលើមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការដាក់ទោសផ្សេងទៀត ឬការធ្វើបាបដែលលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬថោកទាប ("អនុសញ្ញា"[1])។ យោងតាមមេធាវីការពារក្តី អត្ថបទនៃមាត្រានេះ ត្រូវបានបកស្រាយនៅក្រោមលក្ខខណ្ឌយ៉ាងតឹងតែងដូចដែលបានរំលឹកខាងលើ អំពីការប្រើប្រាស់ភស្តុតាងបានមកតាមរយៈការធ្វើទារុណកម្ម។

៣. មេធាវីការពារក្តី យល់ឃើញថា ការបកស្រាយដែលមានលក្ខណៈទូលាយគឺ "*ផ្ទុយនឹងខ្លឹមសារធម្មតានៃបទប្បញ្ញត្តិនេះ បើផ្អែកតាមកម្មវត្ថុ និងគោលបំណងរបស់វា*[2]" និងចំពោះហេតុផលពីរយ៉ាង៖ "*ម្យ៉ាង ព័ត៌មានដែលបានមកដោយការធ្វើទារុណកម្ម មិនអាចជឿទុកចិត្តបាន និងម្យ៉ាងទៀត ការហាមឃាត់មិនឱ្យប្រើប្រាស់ចម្លើយសារភាពដែលបានមកដោយការធ្វើទារុណកម្ម នឹងចូលរួមចំណែកក្នុងការបង្ការទង្វើបែបនេះ*[3]"។

៤. ម្យ៉ាងទៀត មេធាវីការពារក្តីរំលឹកផងដែរថា ការពឹងផ្អែកទៅលើព័ត៌មានដែលមិនអាចជឿទុកចិត្តបាន នឹងរំលោភដល់សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌ និងថាដំណោះស្រាយដែលជួនកាលត្រូវបានធ្វើ ដើម្បីបង្កើតអញ្ញត្រកម្មសម្រាប់អង្គជំនុំជំរះវិសាមញ្ញ ដោយ

---

[1] អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការដាក់ទោសផ្សេងទៀត ឬការធ្វើបាបដែលលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬថោកទាប ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៨៤, 1465 U.N.T.S.85។

[2] D130 កថាខ័ណ្ឌ ៥១។

[3] D130 កថាខ័ណ្ឌ ៤៨ លើកពីគណៈកម្មាធិការ ប្រឆាំងនឹងការធ្វើទារុណកម្ម។ សេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម , កម្ពុជា, ថ្ងៃ ២៧ ឧសភា ២០០៣, ឯកសារអង្គការសហប្រជាជាតិលេខ CAT/C/CR/30/2 (ការកត់សំគាល់ចុងក្រោយ/ការអត្ថាធិប្បាយ)។

សំអាងថា វាគឺជាភស្តុតាង *"ចាំបាច់សម្រាប់ការបង្កើតពិរុទ្ធភាព[4]"* មានប្រៀបជាងការរំលោភការសន្មត ទុកជាមុនថាគ្មានទោស។

## ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា

៥. សហព្រះអាជ្ញា ស្នើសុំសហចៅក្រមស៊ើបអង្កេត៖

ក) បដិសេធសំណើសុំរបស់មេធាវីការពារក្តីទាំងស្រុង

ខ) រក្សាទុកនៅក្នុងសំណុំរឿង ០០២ នូវភស្តុតាងទាំងអស់ដែលត្រូវបានជំទាស់ទាក់ទិននឹងការធ្វើទារុណកម្ម

គ) យល់ព្រមដាក់ចូលទៅក្នុងសំណុំរឿង ០០២ នូវភស្តុតាងទាំងអស់ស្រដៀងគ្នា ដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យដែលបានរៀបរាប់នៅក្នុងការឆ្លើយតបរបស់ខ្លួន។

៦. ជាបឋម សហព្រះអាជ្ញា យោងទៅលើ "គោលការណ៍នៃភាពអាចបត់បែនបាន" ដែលតាមរយៈគោលការណ៍នេះ យុត្តាធិការអន្តរជាតិ ស្ថិតនៅក្រោមវិធានគ្រប់គ្រងភស្តុតាងទន់ភ្លន់ជាងយុត្តាធិការជាតិ។ ជាពិសេស តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់យូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា បានទទួលស្គាល់នូវភស្តុតាងដែលទទួលបានដោយខុសច្បាប់ ឬដោយមិនត្រឹមត្រូវ ឱ្យតែ *"អ្នកដែលប្រមូលភស្តុតាងទាំងនោះ មិនមែនជាបុគ្គលិក ឬភ្នាក់ងាររបស់តុលាការ[5]"*។

៧. ទីពីរ សហព្រះអាជ្ញា ទទូចស្នើសុំឱ្យមានការបកស្រាយទូលាយនូវមាត្រា ១៥ នៃអនុសញ្ញា ដោយអះអាងថា ការយល់ឃើញចង្អៀត នឹងផ្ទុយពីគំនិតចង់បាននៃមាត្រានេះ ៖ *"ការរារាំងចំពោះភស្តុតាងដែលបានតវ៉ា មុខជានឹងលើកទឹកចិត្តដល់អ្នកទាំងឡាយណាដែលបានចូលរួមធ្វើឱ្យមានការធ្វើទារុណកម្ម ដោយអនុញ្ញាតឱ្យពួកគេប្រើប្រាស់ច្បាប់អន្តរជាតិនានាដែលត្រូវបានបង្កើតឡើងដើម្បីទប់ស្កាត់ និងផ្តន្ទាទោសចំពោះការធ្វើទារុណកម្ម ដើម្បីគេចផុតពីការទទួលខុសត្រូវ[6]"*។

---

[4] D130 កថាខ័ណ្ឌ ៣៧ យោងដល់ Michael P. Scharf "Tainted Provenance: ប្រសិនបើអាច តើនៅពេលណាដែលភស្តុតាងនៃអំពើធ្វើទារុណកម្មអាចទទួលយកបាន?" (២០០៨) ៦៥ Washington and Lee Law Review 129 ទំព័រ ១៣៩។

[5] D130/5 កថាខ័ណ្ឌ ១៥ និង១៦។

[6] D130/5 កថាខ័ណ្ឌ ២២។

៨. ទីបី សហព្រះរាជអាជ្ញា អះអាងថា ផ្នែកមួយចំនួននៃព័ត៌មាននៃភស្តុតាងដែលត្រូវបានជំទាស់ទាំងនេះ គឺអាចទទួលយកបានដោយសារមានតម្រុយខ្ពស់បង្ហាញពីភាពអាចជឿទុកចិត្តបានរបស់វាដែលមាន[7]។ សហព្រះរាជអាជ្ញា ក៏បានអះអាងផងដែរថា ចម្លើយសារភាពគឺអាចទទួលយកបាន ដើម្បីប្រឆាំងនឹងជនត្រូវចោទ ដោយមិនគិតថាពួកគេផ្ទាល់បានធ្វើទារុណកម្ម ឬក៏អត់នោះទេ[8]។

៩. ម្យ៉ាងទៀត សហព្រះរាជអាជ្ញា យល់ឃើញថា ទោះបីជាចម្លើយសារភាពត្រូវបានសម្រេចថាមិនអាចទទួលយកបានក៏ដោយ ក៏វាមិនដូចគ្នាដែរសម្រាប់ "ជំនាញការ" ដែលផ្អែកលើចម្លើយសារភាពទាំងនេះ ពីព្រោះ បើតាមតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់យូហ្គោស្លាវី ការព្រួយបារម្ភពីភាពដែលអាចជឿទុកចិត្តបាននៃប្រភពដែលប្រើប្រាស់ដោយអ្នកជំនាញ មិនប៉ះពាល់ដល់ភាពទទួលយកបាននៃរបាយការណ៍របស់ពួកគេឡើយ ប៉ុន្តែអាចប៉ះពាល់ដល់ទម្ងន់ដែលផ្តល់ទៅឲ្យភស្តុតាងទាំងឡាយណាដែលរបាយការណ៍នេះយកមកធ្វើជាសំអាង[9]។

១០. សហព្រះរាជអាជ្ញា គាំទ្រថា យ៉ាងហោចណាស់ ចម្លើយសារភាពទាំងនេះ ត្រូវបានទទួលយកជា "តម្រុយនៃការស៊ើបអង្កេត[10]"។

១១. នៅចុងបញ្ចប់ សហព្រះរាជអាជ្ញា អះអាងថា ចំណារ និងជីវប្រវត្តិនានា មិនមែនបានមកតាមរយៈការធ្វើទារុណកម្មទេ ដូច្នេះគឺជាភស្តុតាងដែលអាចទទួលយកបាន និងមិនប៉ះពាល់ដល់មាត្រា ១៥ នៃអនុសញ្ញាដែរ[11]។

**ការឆ្លើយតបវិញរបស់មេធាវីការពារក្តី**

១២. មេធាវីការពារក្តី បានបញ្ជាក់សារឡើងវិញពីសេចក្តីសន្និដ្ឋានដំបូងរបស់ខ្លួន និងអះអាងថា សហព្រះរាជអាជ្ញា ៖

ក) បានបកស្រាយច្បាប់ខុស[12]

---

[7] D130/5 កថាខ័ណ្ឌ ២៦

[8] D130/5 កថាខ័ណ្ឌ ២៩-៣២

[9] D130/5 កថាខ័ណ្ឌ ៣៣-៣៤

[10] D130/5 កថាខ័ណ្ឌ ៣៥-៣៧

[11] D130/5 កថាខ័ណ្ឌ ៣៨-៤០

[12] D130/6 កថាខ័ណ្ឌ ១៣-១៩

ខ) បានបង្វៀងសំណួរទាក់ទិននឹងការខ្វះភាពគួរឱ្យជឿទុកចិត្តបាននៃភស្តុតាងដែលមានជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម[13]

គ) បានព្យាយាមទាំងខុសដោយសំអាងទៅលើគោលការណ៍នៃភាពអាចបត់បែនបាន ហើយបើតាមមេធាវីការពារក្តី វាមិនអាចអនុវត្តបានទេ បើគិតពីលក្ខណៈមិនអាចផ្តាច់បាននៃភស្តុតាងដែលមានជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម[14]

១៣. មេធាវីការពារក្តី ក៏បានលើកផងដែរថា នៅក្នុងករណីដែលមានការជំទាស់ករណីថា ព័ត៌មានដែលទទួលបាន គឺធ្វើឡើងតាមរយៈការធ្វើទារុណកម្មនោះ ការបង្ហាញភស្តុតាងគឺជាបន្ទុករបស់សហព្រះរាជអាជ្ញា[15]។

១៤. នៅចុងបញ្ចប់ មេធាវីការពារក្តី បានអះអាងម្តងទៀតថា មាត្រា ១៥ នៃអនុសញ្ញា បានទាត់ចោលការរាល់ប្រើប្រាស់ នូវព័ត៌មានទាំងឡាយណាដែលមានការពាក់ព័ន្ធនឹងការធ្វើទារុណកម្ម រួមទាំងយោបល់ជំនាញនានា ដែលប្រើប្រាស់ព័ត៌មានទាំងនេះផងដែរ[16] ។

**សំអាងហេតុនៃសេចក្តីសម្រេច**

១៥. ជាបឋម មានការកត់សំគាល់ចំនួនពីរ៖

១៦. ទីមួយ បញ្ហាដែលលើកឡើងទាំងដោយមេធាវីការពារក្តី[17] និងទាំងដោយសហព្រះរាជអាជ្ញា[18] ចង់ដឹងថាតើជាបន្ទុករបស់អ្នកណាក្នុងការបង្ហាញភស្តុតាង នៅពេលមានការលើកឡើងថា

---

[13] D130/6 កថាខ័ណ្ឌ ២២-២៥

[14] D130/6 កថាខ័ណ្ឌ ២៧ -៣៣

[15] D130/6 កថាខ័ណ្ឌ ២៥

[16] D130/6 កថាខ័ណ្ឌ ៣៦-៤២

[17] ដែលសំអាងលើយុត្តិសាស្ត្រ ដូចជារឿងក្តី *A និងអ្នកដទៃ ទល់នឹងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ* , [២០០៥] UKHL ៧១ (*"A និងអ្នកដទៃ")* និងការរិះគន់របស់អ្នករាយការណ៍ពិសេស សម្រាប់ការធ្វើទារុណកម្ម លើរឿងក្តីអាល្លឺម៉ង់ *Mounir el Motassdeq* (*Beschluss IV-1/04 des Hanseatischen Oberlandesgericht Hamburg,* Neue Juristiche Wochenschrift 2005 Heft 32, ១៤ មិថុនា ២០០៥)- មហាសន្និបាតអង្គការសហប្រជាជាតិ, ការធ្វើទារុណកម្ម និងការដាក់ទោសផ្សេងទៀត ឬការធ្វើបាបដែលលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬថោកទាប។ UN Doc. No. A/61/259, ១៤ សីហា ២០០៦ ទំ. ១៧។

ចម្លើយសារភាពមួយត្រូវបានធ្វើក្រោមរូបភាពនៃការធ្វើទារុណកម្ម និងពីភាពគួរឱ្យជឿទុកចិត្តនៃចម្លើយសារភាពនោះ មិនមានសារៈសំខាន់សម្រាប់ អ.វ.ត.ក ដូចនៅយុត្តាធិការអន្តរជាតិដទៃទៀតដែលយកគំរូតាមប្រព័ន្ធ Common Law ទេ នេះបើគិតពីតួនាទីសកម្មរបស់សហចៅក្រមស៊ើបអង្កេតក្នុងការស្វែងរក និងវិភាគភស្តុតាង[19]។

១៧. បញ្ហាទីពីរ គឺថា ក្នុងវិធានផ្ទៃក្នុង មិនមានទូវបញ្ញត្តិពិសេស ឆ្លើយតបទៅនឹងបញ្ហា ដែលលើកឡើងក្នុងសំណើសុំនោះទេ ជាក់ស្តែងវិធានដែលទាក់ទងនឹងលទ្ធភាពក្នុងការប្រើប្រាស់នូវភស្តុតាង ដែលបាត់បង់នូវតម្លៃដោយសារការធ្វើទារុណកម្ម នៅពេលដែលភស្តុតាងទាំងនោះ ទទួលបានដោយស្ថាប័នផ្សេងពីអង្គជំនុំជម្រះវិសាមញ្ញ។ វិធាន ២១.១ នៃវិធានផ្ទៃក្នុងចែងថា៖ *"គ្មានទម្រង់ណាមួយនៃការជំរុញទឹកចិត្ត ការបង្ខំលើរាងកាយ ឬការគំរាមកំហែងត្រូវបានយកទៅអនុវត្តក្នុងពេលធ្វើសម្ភាសន៍ចំពោះអ្នកដែលត្រូវបានសួរយកចម្លើយ ឬអ្នកដទៃទៀតឡើយ"* ពិតណាស់ បញ្ញត្តិនេះអនុវត្តតែចំពោះចម្លើយសារភាព ដែលទទួលបានដោយអង្គជំនុំជម្រះវិសាមញ្ញតែប៉ុណ្ណោះ មិនសំដៅដល់ចម្លើយសារភាពដែលទទួលបាននៅក្រោមបក្សកុម្មុយនិស្តកម្ពុជា (បកក) ដែលកន្លងទៅជាង ៣០ ឆ្នាំហើយនោះទេ។ យោងតាមអ្វីដែលបានរៀបរាប់មកខាងលើ និងដោយពិនិត្យលើភាពមិនច្បាស់លាស់នៃការបកស្រាយលើបទប្បញ្ញត្តិនៃច្បាប់កម្ពុជា[20] ជាពិសេស ដោយអនុលោមតាម មាត្រា ១២(១) នៃកិច្ចព្រមព្រៀងរវាង

---

[18] D130/5 កថាខ័ណ្ឌ ២៧។

[19] Tobias Thieniel បញ្ជាក់លើចំនុចនេះថា *"មិនមានបទប្បញ្ញត្តិនៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការដាក់ទោសផ្សេងទៀត ឬការធ្វើបាបដែលលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬថោកទាប ទាក់ទិននឹងបន្ទុកក្នុងការបង្ហាញភស្តុតាង អាចត្រូវបានលើកឡើងនៅក្នុងការកាត់ក្តីរឿងព្រហ្មទណ្ឌដែលមានកិច្ចស៊ើបសួរទេ។ កាតព្វកិច្ចបែបនេះមិនធ្លាក់ទៅលើជនជាប់ចោទទេ ព្រោះនៅក្នុងប្រព័ន្ធបែបនេះ វាជាការងាររបស់ចៅក្រម គឺមិនមែនជនជាប់ចោទ ឬសហព្រះរាជអាជ្ញាទេ ក្នុងការចង្អុលភស្តុតាងពីអង្គហេតុ។"* Tobias Thienel, "ភាពទទួលយកបាននៃភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម នៅក្រោមច្បាប់អន្តរជាតិ" ("The Admissibility of Evidence Obtained by Torture Under International Law"), (២០០៦) 17 EJIL 349; ទំ. ៣៥៤។

[20] សហព្រះរាជអាជ្ញាលើកឡើងថា មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា *"ការទទួលសារភាព ដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តីតាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ"* និងមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា *"ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភស្តុតាងទេ។"* ច្រានចោលនូវលទ្ធភាពនៃការលើកឡើងនូវភស្តុតាង ដែលទទួលបានដោយការធ្វើទារុណកម្ម ប្រឆាំងនឹងជនរងគ្រោះនៃអំពើទារុណកម្មនោះតែប៉ុណ្ណោះ (D130/5 កថាខណ្ឌ ០៦)។ ផ្ទុយទៅវិញ ក្រុមមេធាវីការពារក្តី បានលើកឡើងថា បទប្បញ្ញត្តិទាំងនេះ មិនត្រឹមតែអនុវត្តចំពោះជនត្រូវចោទដែលជាជនរងគ្រោះនៃអំពើទារុណកម្មប៉ុណ្ណោះទេ តែវាក៏អនុវត្តផងដែរចំពោះជនត្រូវចោទគ្រប់រូប នៅក្នុង ដំណើរការរឿងក្តីព្រហ្មទណ្ឌ (D130/6 កថាខណ្ឌ ១៤ ដល់ ១៥ )។

អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៦ មិថុនា ២០០៣[21] និងមាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[22] វាតម្រូវឱ្យមានការអនុវត្តន៍នូវវិធាននីតិវិធី ដែលមានលក្ខណៈជាអន្តរជាតិ ជាក់ស្តែងគឺ មាត្រា ១៥ នៃអនុសញ្ញាស្តីពីអំពើទារុណកម្ម។

១៨. អនុលោមតាមបញ្ញត្តិនៃមាត្រានេះ៖ *"គ្រប់រដ្ឋជាភាគីត្រូវធានាថា គ្រប់ចម្លើយសារភាពទាំងឡាយណា ដែលត្រូវបានបង្ហាញថាទទួលបានដោយអំពើទារុណកម្ម មិនអាចត្រូវបានលើកឡើង ជាភស្តុតាងនៅក្នុងដំណើរការនីតិវិធី លើកលែងចំពោះតែការលើកឡើងជាភស្តុតាងប្រឆាំងនឹងជនដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើទារុណកម្ម ដើម្បីបញ្ជាក់ថា មានការបង្ខំឱ្យឆ្លើយសារភាព"*។

១៩. មុននឹងធ្វើការវិភាគអំពីវិសាលភាពនៃមាត្រានេះ សូមធ្វើការបញ្ជាក់ថា មាត្រានេះអនុវត្តចំពោះតែភស្តុតាងទាំងឡាយណា ដែលត្រូវបានបញ្ជាក់ថា *"ទទួលបានដោយការធ្វើទារុណកម្ម"* តែប៉ុណ្ណោះ ផ្ទុយទៅវិញឯកសារដែលបានលើកឡើងនៅក្នុងរឿងនេះ មានផ្ទុកនូវព័ត៌មានមួយចំនួន ដែលមិនមែនទទួលបានដោយអំពើធ្វើទារុណកម្ម។ ជាក់ស្តែង ដូចជាចំណារសរសេរដៃមួយចំនួន ដែលមាននៅក្នុង ចម្លើយសារភាព ដែលត្រូវបានបញ្ជាក់ថាមិនត្រូវបានទទួលដោយការធ្វើទារុណកម្ម ប៉ុន្តែ ត្រូវបានធ្វើដោយអ្នកធ្វើទារុណកម្មខ្លួនឯង ដោយបុគ្គលិកផ្សេងទៀតរបស់មន្ទីរស២១ ឬដោយជនត្រូវចោទ ប៉ុន្តែដាច់ខាត គឺមិនមែនដោយជនរងគ្រោះនៃអំពើទារុណកម្មនោះទេ[23]។ ឯកសារទាំងនោះ ក៏រួមបញ្ចូលផងដែរនូវចម្លើយសារភាពទាក់ទងនឹងប្រវត្តិរូប ក្នុងលក្ខខណ្ឌដែលថា វាត្រូវបានធ្វើឡើងនៅពេលដែលជននោះត្រូវបានបញ្ជូនមកដល់មន្ទីរស២១ គឺនៅពេលកត់ឈ្មោះចូលក្នុងបញ្ជី មិនមែនក្នុងក្របខណ្ឌនៃការសួរចម្លើយដើម្បីទទួលបាននូវចម្លើយសារភាពនោះទេ។ ទាំងនេះគឺជាអ្វី ដែលក្រុមមេធាវីការពារក្តីបានទទួល

---

[21] មាត្រា ១២(១) ចែងថា៖ *"នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា។ នៅពេលណាដែលច្បាប់កម្ពុជា ពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទ ប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នា រវាងបទប្បញ្ញត្តិបែបនេះ ទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។"*

[22] មាត្រា ២៣ ថ្មី *"ប្រសិនបើនីតិវិធី ដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនិតិវិធីទាំងនេះ ជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើង ក្នុងកម្រិតអន្តរជាតិ។"*

[23] បញ្ហាយថាភាពនៃចំណារសរសេរដៃទាំងនេះ (សូមមើល D130/6 កថាខណ្ឌ ៤២) គឺជាកម្មវត្ថុនៃការពិភាក្សា ដោយឡែក។



CO-INVESTIGATING JUDGES *E.C.C.C*

ស្គាល់[24]។ ត្រូវបានចាត់ទុកថា ឋិតនៅក្នុងប្រភេទដូចគ្នានឹងឯកសារខាងលើនេះដែរ ចំពោះព័ត៌មានសត្យានុម័តនានា ដែលមានក្នុងចម្លើយសារភាព និងទទួលបានដោយមិនមានការពាក់ព័ន្ធជាមួយនឹងការសួរចម្លើយ ជាពិសេសដូចជាកាលបរិច្ឆេទនៃការចាប់ខ្លួន កាលបរិច្ឆេទនៃការចាប់ផ្តើម ការបញ្ចប់ ឬការផ្អាកការផ្តល់នូវចម្លើយសារភាព និងរួមទាំងព័ត៌មានផ្សេងៗទៀត ដែលទាក់ទងនឹងប្រវត្តិរូប ដូចជា ឈ្មោះ អាយុ មុខងារ ឬអង្គភាពការងាររបស់ជន ដែលទទួលរងនូវអំពើទារុណកម្ម។ ដូច្នេះ ឯកសារ ឬព័ត៌មានទាំងអស់ខាងលើ ដែលមិនមែនទទួលបានដោយអំពើទារុណកម្ម មិនមានជាប់ពាក់ព័ន្ធជាមួយនឹងការអនុវត្តន៍បញ្ញត្តិនៃមាត្រា ១៥ នៃអនុសញ្ញានោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ពិតមែនតែព័ត៌មានទាំងនេះមិនត្រូវបានទទួលដោយអំពើទារុណកម្ម តែវាក៏អាចទទួលបានក្នុងកាលៈទេសៈមួយចំនួន ដូចជាការបង្ខិតបង្ខំ (សាក្សីអាចដឹងថាពួកគេកំពុងឋិតនៅក្នុងពេលជិតទទួលរងនូវអំពើទារុណកម្ម) ឬថា សាក្សីមានហេតុផលក្នុងការមិននិយាយពីការពិត (ដូចជាការចង់លាក់បាំងអំពីព័ត៌មាន ដែលទាក់ទងនឹងដើមកំណើតជាតិសាសន៍ ឬសាសនារបស់ខ្លួន)។ ទោះបីជាការប្រើប្រាស់នូវព័ត៌មានទាំងនេះមិនត្រូវបានហាមឃាត់ដោយបញ្ញត្តិនៃមាត្រា ១៥ នៃអនុសញ្ញាក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតនឹងធ្វើការពិចារណាលើទិដ្ឋភាពទាំងនេះ ដើម្បីវាយតម្លៃអំពីភាពដែលអាចជឿជាក់បាន និងការប្រើប្រាស់ដោយត្រឹមត្រូវនៃភស្តុតាងទាំងនេះ។

២០. ទាក់ទងនឹងភស្តុតាង ដែលពិតជាទទួលបានដោយអំពើទារុណកម្មវិញ មាត្រា ១៥ នៃអនុសញ្ញា បានអនុញ្ញាតនៅក្នុងអញ្ញត្រកម្មរបស់ខ្លួនឱ្យប្រើប្រាស់នូវភស្តុតាងទាំងនេះ *"ប្រឆាំង នឹងជនត្រូវចោទលើអំពីទារុណកម្ម ដើម្បីបញ្ជាក់ថា ចម្លើយសារភាពពិតជាត្រូវបានធ្វើឡើង"*។ ចាំបាច់ ត្រូវមានការបកស្រាយលើខ្លឹមសារ និងវិសាលភាពនៃអញ្ញត្រកម្មនេះ។

២១. វាប្រាកដហើយថា អញ្ញត្រកម្មនេះមិនអនុញ្ញាតឱ្យមានការលើកឡើងនូវចម្លើយសារភាពដែលទទួលបានដោយអំពើទារុណកម្ម ដើម្បីប្រឆាំងនឹងជនរងគ្រោះនៃអំពើទារុណកម្ម ឬដើម្បីប្រឆាំងនឹងតតិយជន ដែលត្រូវបានចោទប្រកាន់ដោយជនដែលត្រូវបានគេធ្វើទារុណកម្មនោះទេ។ ដូច្នេះ នៅក្នុងរឿងនេះ បញ្ហានៃរបៀបនៃការប្រើប្រាស់ភស្តុតាង ឬការព្រួយបារម្ភដ៏ត្រឹមត្រូវរបស់អាជ្ញាធរមួយចំនួន

[24] នៅក្នុងសំណើសុំរបស់ខ្លួន ក្រុមមេធាវីការពារក្តីមិនបានជំទាស់ទេ ចំពោះរឿងដែលថា ព័ត៌មានដែលទាក់ទងនឹងជីវប្រវត្តិ និងដែលទទួលបានមុនពេលមានអំពើទារុណកម្ម ត្រូវបានគេរាប់បញ្ចូលដែរនោះ (សូមមើល D130 កថាខណ្ឌ ៤២)។ ទោះជាយ៉ាងនេះក៏ដោយ នៅក្នុងចម្លើយតបរបស់ខ្លួន ក្រុមមេធាវីការពារក្តីហាក់ដូចជាជំទាស់ចំពោះការវិភាគ ដែលបង្ហាញថា ព័ត៌មានទាំងនេះមិនត្រូវបានទទួលដោយអំពីទារុណកម្មនោះទេ និងបានលើកឡើងថា វាជាកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការលើកឡើងពីភស្តុតាងផ្ទុយ។ (សូមមើល D130/6 កថាខណ្ឌ ៤០)

ទាក់ទងនឹងសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង[25] មិនចាំបាច់ត្រូវពិភាក្សាវែកញែកនោះទេ ព្រោះវាត្រឹមត្រូវអស់ទៅហើយ។ ហេតុផលដូចគ្នានេះ ត្រូវបានគេអនុវត្តនៅក្នុងសេចក្តីសម្រេចរបស់តុលាការកំពូលប្រទេសអង់គ្លេស ក្នុងរឿងក្តី *Chambre des Lords A និង ជនផ្សេងទៀត* ទាក់ទងនឹងបញ្ហានៃការប្រើប្រាស់ចម្លើយសារភាពដែលទទួលបានដោយអំពើទារុណកម្មធ្វើឡើងដោយតតិយជន និងការប្រើប្រាស់ចម្លើយសារភាពនេះដើម្បីប្រឆាំងនឹងជនត្រូវចោទ ដែលត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពនៃជនរងគ្រោះនៃអំពើទារុណកម្ម។

**២២.** វាក៏ជារឿងច្បាស់លាស់ផងដែរ ចំពោះរឿងដែលថា បញ្ញត្តិនេះអនុញ្ញាតឱ្យមានការប្រើប្រាស់នូវចម្លើយសារភាពទាំងនេះ ដើម្បីប្រឆាំងនឹង *"ជនត្រូវចោទលើអំពើទារុណកម្មតែ ប៉ុណ្ណោះ"*។ ចំពោះចំណុចនេះ ក្រុមមេធាវីការពារក្តីបានលើកឡើងថា ខ្លឹមសារនៃមាត្រា ១៥ បាន ហាមឃាត់នូវការប្រើប្រាស់ភស្តុតាង ដែលទទួលបានដោយអំពើទារុណកម្មប្រឆាំងនឹងគ្រប់ជនទាំងអស់ ដែលមានដូចជាជនដែលត្រូវបានចោទប្រកាន់លើមូលដ្ឋាននៃការទទួលខុសត្រូវក្នុងឋានៈ ជាមេកើយ និងអ្នកដែលបានចូលរួមក្នុងការប្រព្រឹត្តសហឧក្រិដ្ឋកម្មរួម ដោយលើកលែងតែជនដែលបានធ្វើអំពើទារុណកម្មដោយផ្ទាល់តែប៉ុណ្ណោះ[26]។ ការបកស្រាយបែបនេះ ដោយ ក្រុមមេធាវីការពារក្តី មិនអាចទទួលយកបានទេ។ យើងមិនយល់ទាល់តែសោះហេតុអ្វីបានជាអាចប្រឆាំងបានតែចំពោះជន ដែលបានធ្វើអំពើទារុណកម្មដោយផ្ទាល់ ខណៈដែលបុគ្គលម្នាក់អាចត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើទារុណកម្ម ដោយផ្អែកលើទំរង់នៃការទទួលខុសត្រូវជាច្រើនផ្សេងៗគ្នា។ គោលបំណងមួយរបស់មាត្រា ១៥ នៃអនុសញ្ញា គឺការបង្ការទប់ស្កាត់កុំឱ្យមានជនប្រព្រឹត្តអំពើទារុណកម្ម ដូច្នេះវាមិនមែនជារឿងត្រឹមត្រូវទេ ក្នុងការដែលកំណត់ដែនអនុវត្ត ត្រឹមតែចារីផ្ទាល់នៃអំពើទារុណកម្ម គឺត្រូវទប់ស្កាត់ផងដែរនូវអំពើទារុណកម្មដែលកើតឡើងពីសំណាក់ជនដែលឋានៈខ្ពស់បំផុតនៅក្នុងខ្សែសង្វាក់នៃការបញ្ជា និងជាអ្នកទទួលខុសត្រូវលើនយោបាយទារុណកម្ម ដែលត្រូវបានអនុវត្តដោយអ្នកដែលនៅក្រោមបញ្ជាខ្លួន។

---

[25] គណៈកម្មការប្រឆាំងនិងអំពើទារុណកម្ម សេចក្តីសន្និដ្ឋាន និងអនុសាសន៍របស់គណៈកម្មាធិការប្រឆាំងនឹងអំពើ ទារុណកម្ម កម្ពុជា ២៧ ឧសភា ២០០៣ ឯកសារអង្គការសហប្រជាជាតិលេខ CAT/C/CR/30/2 (ការកត់សម្គាល់ស្ថាពរ/យោបល់អធិប្បាយ) Redress, *"Bringing the International Prohibition against Torture Home: National Implementation Guide for the UN Convention Against Torture and other Cruel, Inhuman or Degrading Treatment or Punishment"*, The Redress Trust: ក្រុងឡុង (មករា ២០០៦) ទំព័រ ៦២-៦៣

[26] D130 កថា. ៤៥

00355914



**២៣.** ជាងនេះទៅទៀត ការបកស្រាយលើស្មារតីរបស់ច្បាប់ មិនត្រូវគិតតែទៅលើតួអក្សរដោយឯកឯងនោះទេ។ អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា មានខ្លឹមសារយ៉ាងដូច្នេះ ថា៖ *"សន្ធិសញ្ញាមួយត្រូវតែបកស្រាយដោយសុទ្ធចិត្ត យោងទៅតាមអត្ថន័យធម្មតារបស់បញ្ញត្តិ នៃសន្ធិសញ្ញានោះ នៅក្នុងបរិបទរបស់វា និងដោយផ្អែកតាមកម្មវត្ថុ និងគោលបំណងរបស់វា[27]"*។ អនុសញ្ញាស្តីពីអំពើទារុណកម្មមានគោលបំណងក្នុងការលុបបំបាត់ និងបង្ការកុំឱ្យមានការប្រើប្រាស់អំពើអមនុស្សធម៌នេះ ក៏ដូចជាធ្វើការបង្ក្រាប និងដាក់ទណ្ឌកម្ម[28] លើជនដែលបានប្រព្រឹត្តអំពើនេះផងដែរ។ បើយោងតាមរបាយការណ៍ពិសេសស្តីពីអំពើទារុណកម្ម បញ្ញត្តិនៃមាត្រា ១៥ ផ្អែក លើគោលការណ៍ពីរគឺ៖

ក) ការហាមឃាត់មិនឱ្យមានការប្រើប្រាស់នូវភស្តុតាង ដែលទទួលបានដោយអំពើ ទារុណកម្មនៅរឿងចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ជាកត្តាមួយយ៉ាងធំក្នុងការជួយទប់ស្កាត់ កុំឱ្យមានការប្រើប្រាស់អំពើទារុណកម្ម ដូច្នេះ វាគឺជាកម្លាំងមួយដែលចូលរួមទប់ស្កាត់បង្ការកុំឱ្យ មានការប្រព្រឹត្តអំពើនេះ។

ខ) ជាទូទៅ ភស្តុតាង ដែលទទួលបានដោយអំពើទារុណកម្ម មិនមានតម្លៃល្អគ្រប់គ្រាន់ ដើម្បីយកមកប្រើប្រាស់នៅក្នុងនីតិវិធីតុលាការនោះទេ[29]។

**២៤.** ចំពោះចំណុច "ក" នេះ វាជាក់ច្បាស់ណាស់ថា នៅក្នុងរឿងនេះ ប្រសិនបើយើងហាមឃាត់មិនឱ្យមានការប្រើប្រាស់នូវភស្តុតាងទាំងអស់នោះ គឺមិនត្រឹមតែមិនមានអនុភាពក្នុងការទប់ស្កាត់ រារាំងមិនឱ្យមានការប្រព្រឹត្តអំពើទារុណកម្មនោះទេ[30] ផ្ទុយទៅវិញវាបែរជាអនុញ្ញាតឱ្យជនដែលរងការចោទប្រកាន់ពីបទទារុណកម្មនេះ អាចប្រើប្រាស់បញ្ញត្តិច្បាប់នេះ ដើម្បីគេចពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទៅវិញ។ ដូច្នេះការបកស្រាយបញ្ញត្តិនៃមាត្រា ១៥ ដោយផ្អែកតែទៅលើតួអក្សរ អាចត្រលប់ទៅជាការពារជនដែលធ្វើអំពើទារុណកម្ម ហើយវាត្រលប់ទៅជាការជម្រុញទឹកចិត្ត ជាជាងការបង្ការកុំឱ្យមានការអនុវត្តនយោបាយទារុណកម្មទៅវិញ។ ការបកស្រាយដូច្នេះ គឺវាផ្ទុយទៅនឹងគោលបំណងនៃមាត្រា ១៥ ក៏ដូចជាបទប្បញ្ញត្តិទាំងមូលនៃអនុសញ្ញា។

---

[27] អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់នៃសន្ធិសញ្ញា ចុះថ្ងៃទី ២៣ ឧសភា ១៩៦៩ 1155 U.N.T.S. 331, 8 I.L.M. 679 មាត្រា ៣១។

[28] អនុសញ្ញាស្តីពីអំពើទារុណកម្ម មាត្រា ៤-៩, ១៤។

[29] មហាសន្និបាតអង្គការសហប្រជាជាតិ ស្តីពីអំពើទារុណកម្ម និងទណ្ឌកម្មផ្សេងៗទៀត ឬការធ្វើបាប ដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬថោកទាប ឯកសាររបស់អង្គការសហប្រជាជាតិ លេខ A/61/259 ១៤ សីហា ២០០៦ កថាខណ្ឌ ៤៥។

[30] សូមរំលឹកថា ចម្លើយសារភាពទាំងនេះ ដែលមានអាយុកាលប្រហែល ៣០ ឆ្នាំមកហើយ មិនមែនបានមកដោយអង្គជំនុំជម្រះវិសាមញ្ញ ឬអាជ្ញាធរណាមួយដែលដើរតួនាទីជំនួសអង្គជំនុំជម្រះវិសាមញ្ញនោះឡើយ។



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C. * CO-JUGES

00355915



**២៥.** ចំពោះចំណុច "ខ" វិញ យើងអាចនិយាយបានថា បញ្ហានៃភាពដែលអាចគួរឱ្យជឿជាក់បាន នឹងមិនកើតមានទេ ប្រសិនបើចម្លើយសារភាពទាំងនោះត្រូវបានប្រើប្រាស់ តាមរបៀបពីរយ៉ាងដូចខាងក្រោម៖

**២៦.** របៀបទី ១ វាមិនមានការហាមឃាត់នោះទេ ប្រសិនបើព័ត៌មាន ដែលមានក្នុងចម្លើយសារភាពនោះត្រូវបានប្រើប្រាស់ដើម្បីជា "តំរុយនៃការស៊ើបអង្កេត" ទៅរកប្រភពព័ត៌មានផ្សេងដទៃទៀត ហើយបើទោះជាចុងក្រោយ ចម្លើយសារភាពនេះមិនអាចត្រូវបានគេចាត់ទុកថា អាចគួរឱ្យជឿជាក់បានក៏ដោយ។ មួយភាគធំនៃភស្តុតាង ដែលប្រើប្រាស់ដើម្បីជាតំរុយនៃការស៊ើបអង្កេត គឺមិនមានភាពអាចគួរឱ្យជឿជាក់បាននោះទេ ហើយនឹងមិនត្រូវបានគេប្រកាន់យកជាធាតុផ្សំក្នុងការតាក់តែងដីកាដំណោះស្រាយនោះឡើយ។ នេះមានន័យថា នៅក្នុងដំណើរការនៃកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតមិនត្រូវធ្វើការច្រានចោលសម្ភតិកម្មណាមួយឡើយ ហើយវាមិនមែនជាការចាំបាច់ទេ ដែលសហចៅក្រមស៊ើបអង្កេតត្រូវប្រកាន់យកអ្វី ដែលមាននៅក្នុងចម្លើយសារភាព ដើម្បីបង្កើតរបៀបរបបថ្មីក្នុងការស្វែងរកការពិត។ ធ្វើដូច្នេះ មិនប៉ះពាល់ដល់បូរណភាពនៃនីតិវិធីនោះឡើយ។

**២៧.** របៀបទី ២ បញ្ហានៃភាពដែលអាចគួរឱ្យជឿជាក់បាននៃភស្តុតាង ដែលមានក្នុងចម្លើយសារភាព នឹងមិនកើតមានទេ ប្រសិនបើព័ត៌មានដែលទទួលបាននោះត្រូវបានប្រើប្រាស់មិនមែនដើម្បីបញ្ជាក់ថា ខ្លឹមសារនោះជាការពិត ឬមិនមែន ប៉ុន្តែគ្រាន់តែដើម្បីបង្ហាញថា ប.ក.ក. បានប្រើប្រាស់ចម្លើយសារភាពដើម្បីប្រព្រឹត្តនូវឧក្រិដ្ឋកម្ម ដែលមានលក្ខណៈជាប្រព័ន្ធ និងឋិតនៅក្នុងសមត្ថកិច្ចយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ ឧទាហរណ៍ ប្រសិនបើនៅក្នុងចម្លើយសារភាពមួយមានបញ្ជីឈ្មោះមនុស្ស ដែលត្រូវបានបរិហារថាជា "ជនក្បត់" ដោយជនរងគ្រោះនៃអំពើទារុណកម្ម និងបន្ទាប់មកប្រសិនបើមានការបង្ហាញថា ជនដែលត្រូវបានគេឆ្លើយដាក់នោះត្រូវបានគេចាប់ខ្លួន ឬសម្លាប់ក្នុងពេលក្រោយមកទៀត ចម្លើយសារភាពបែបនេះពិតជាអាចបង្ហាញឱ្យឃើញថា អ្នកទទួលអានចម្លើយសារភាពបន្ត បានផ្អែកលើចម្លើយសារភាពនេះដើម្បីបញ្ជាឱ្យមានការចាប់ខ្លួន ឬការសម្លាប់ជាលក្ខណៈប្រព័ន្ធ។ គួរបញ្ជាក់ថា ត្រង់ចំណុចនេះ ព័ត៌មានដែលមានក្នុងចម្លើយសារភាពនេះ មិនត្រូវបានគេប្រើប្រាស់ដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវពិតប្រាកដនៃខ្លឹមសារនោះទេ (ថាតើជនដែលត្រូវបានគេឆ្លើយដាក់នោះជាជនក្បត់ពិតប្រាកដមែន ឬយ៉ាងណា) ប៉ុន្តែដើម្បីបង្ហាញអំពីរបៀបនៃការប្រើប្រាស់វា (ប្រព្រឹត្តឧក្រិដ្ឋកម្មលើជនដែលត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពនោះ)។ ដូច្នេះ សរុបមកភាពដែលអាចគួរឱ្យជឿជាក់បាននៃចម្លើយសារភាពទាំងនោះ មិនមានសារៈសំខាន់នោះទេ។

00355916



**២៨.** ផ្ទុយទៅវិញ បញ្ហានៃភាពដែលអាចគួរឲ្យជឿជាក់បាន នឹងកើតមានប្រសិនបើយើងចង់រកឲ្យឃើញខុសត្រូវចំពោះខ្លឹមសារនៃចម្លើយសារភាពនោះ។ ចំពោះចំណុចនេះ ជាគោលការណ៍ សហចៅក្រមស៊ើបអង្កេតមានការយល់ដឹងច្បាស់លាស់ណាស់អំពីតម្លៃ ដែលមិនគួរឲ្យជឿជាក់បានរបស់ភស្តុតាង ដែលទទួលបានដោយការធ្វើទារុណកម្ម។ ផ្ទុយទៅវិញ ក្រៅអំពីចំណុចដែលថា ព័ត៌មាន ដែលមានក្នុងចម្លើយសារភាពទាំងនោះត្រូវបានទទួលដោយការប្រព្រឹត្តអំពើទារុណកម្ម ត្រឹមដំណាក់កាលនេះ យើងអាចត្រឹមតែធ្វើការអះអាងថា មិនមានព័ត៌មានណាមួយ ដែលបានបង្ហាញពីការពិតនៅក្នុងចម្លើយសារភាពទាំងនោះនៅឡើយទេ។ ការវាយតម្លៃអំពីភាពដែលអាចគួរឲ្យជឿជាក់បានអាចធ្វើទៅបាន បន្ទាប់ពីការបិទកិច្ចស៊ើបសួរតែប៉ុណ្ណោះ គឺនៅពេលដែលសំណុំរឿងពេញលេញគ្រប់គ្រាន់។ ដូចគ្នានឹងភស្តុតាងទាំងអស់ដែលមានក្នុងសំណុំរឿងដែរ ភាពដែលអាចគួរឲ្យជឿជាក់បាននៃចម្លើយសារភាព នឹងត្រូវបានគេវាយតម្លៃ មួយករណីម្តងៗ។ សូមបញ្ជាក់ផងដែរថា ដោយយោងលើប្រភេទនៃភស្តុតាងទាំងនេះ និងមធ្យោបាយ ដែលវាទទួលបាន សហចៅក្រមស៊ើបអង្កេតនឹង ពិចារណាយកឯកសារទាំងនេះមកធ្វើជាភស្តុតាងដោយភាពប្រយ័ត្នប្រយែងបំផុត។

**២៩.** ដូចគ្នានេះដែរ ចាំបាច់ត្រូវឲ្យមានការពិនិត្យមួយករណីម្តងៗ ដើម្បីធ្វើការវាយតម្លៃអំពីភាពដែលអាចគួរឲ្យជឿជាក់បានរបស់ភស្តុតាងទាំងនោះ ក៏ដូចជារបាយការណ៍ ឬភស្តុតាងបន្ទាប់បន្សំផ្សេងៗទៀតនៃសំណុំរឿង ដែលផ្អែកមួយផ្នែក ឬទាំងមូល លើព័ត៌មានដែលទទួលបានដោយអំពើទារុណកម្ម[31]។ ប្រសិនបើ បន្ទាប់ពីការត្រួតពិនិត្យនេះ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ចម្លើយសារភាព ដែលរបាយការណ៍ ឬភស្តុតាងបន្ទាប់បន្សំនេះផ្អែកលើ មានភាពខ្វះចន្លោះមិនគួរ

[31] តួយ៉ាងដូចជាព័ត៌មានមួយចំនួន ដែលមានក្នុងភស្តុតាងដូចខាងក្រោម៖ [លុបចោល] [redacted]

ឲ្យជឿជាក់បាន នោះសហចៅក្រមស៊ើបអង្កេតនឹងធ្វើការវាយតម្លៃលើភស្តុតាងបន្ទាប់បន្សំនេះ ដោយយោងលើសេចក្តីសន្និដ្ឋាននេះ ដែលវានឹងធ្វើឲ្យប៉ះពាល់ដល់តម្លៃនៃភស្តុតាងនេះ នៅក្នុងដំណាក់កាលនៃការវិភាគចុងក្រោយ។

៣០. អនុលោមតាមអ្វីដែលបានរៀបរាប់មកទាំងអស់ខាងលើនេះ អំណះអំណាងទាំងឡាយរបស់មេធាវីការពារក្តីស្តីពីការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម មិនអាចទទួលយកបានទេ។

**ហេតុដូច្នេះសម្រេច**

**បដិសេធសំណើសុំរបស់ក្រុមមេធាវីការពារក្តី។**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩

សហចៅក្រមស៊ើបអង្កេត

យូ ប៊ុនឡេង Marcel LEMONDE